**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ ១៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសំរួលឯកសណ្ឋាន និងផ្លាកសញ្ញា របស់នគរបាលជាតិកម្ពុជា

---

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ ន.ស៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម ០១៩៦.០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត ០៣៩៨.០៨៣ ចុះថ្ងៃទី ០៦ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពី រូបភាព លំដាប់សក្តិរបស់កងកម្លាំងនគរបាលជាតិ
- បានឃើញអនុក្រឹត្យលេខ ០៨ អនក្រ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីឯកសណ្ឋាន និងផ្លាកសញ្ញារបស់នគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សំរេច

**មាត្រា ១:** ឯកសណ្ឋាននគរបាលជាតិកម្ពុជា ត្រូវបានកំណត់ដូចខាងក្រោម :

១-រូបភាព និងខ្នាតឯកសណ្ឋាន :

*ក. ឯកសណ្ឋានថ្នាក់ឧត្តមសេនីយ៍ : មាន ០៧ ប្រភេទគឺ :*

ក/១. ឯកសណ្ឋានធំលេខ ១ : " កុដស "

១-ឯកសណ្ឋានធំលេខ១ អាវកុដស សំរាប់ប្រើប្រាស់ក្នុងព្រះរាជពិធីផ្សេង ៗ ។

២-រូបភាព និងម៉ូត :

-អាវកុដស : ក ត្រង់ដៃវែង កាត់រាងអាវធំ មានប៉ូលស្មា និងគ្មានឆែកខ្នង ។

ចុងក អាវទាំងសងខាងមានក្បាច់កំរងកូរស្រូវពណ៌មាស បណ្តោយប្រវែង ៥ ស.ម ទទឹង ៣ ស.ម ។ អាវនេះមានហោប៉ៅចំនួនបួនគឺ ហោប៉ៅខាងលើមានពីរ ( ហោប៉ៅប៉ះ ) តួហោប៉ៅមូលចំកណ្តាល ហោប៉ៅមានជីបផ្នត់មួយ គំរបហោប៉ៅរាងចតុកោណកែង តែចុងគំរបសងខាង និងកណ្តាលរាងស្រួច ហើយមានឡេវរូបព្រះសង្ហារពណ៌មាស ។

ហោប៉ៅខាងក្រោមមានពីរ ( ហោប៉ៅកាត់ ) គំរបហោប៉ៅរាងចតុកោណកែង ជ្រុងពីរខាងក្រោមរាងមូល ។

ពីចុងដៃអាវប្រវែង ៦.៥ ស.ម មានប៉ានក្រណាត់ពណ៌មាសព័ទ្ធជុំវិញដៃអាវ និងមានឡេវរូបព្រះសង្ហារពណ៌មាសចំនួន បីគ្រាប់ដាក់បញ្ឆោត ។

-ខោ : ជើងវែងពណ៌ខ្មៅ ចង្កេះត និងគ្មានភ្លី ។ ហោប៉ៅខោមានចំនួនបីគឺ ហោប៉ៅខាងក្រោយមានចំនួនមួយ ( ហោប៉ៅកាត់ ) គ្មានគំរប ចោះរន្ធដាក់ឡេវមួយគ្រាប់ ហោប៉ៅចំហៀងសងខាងមានចំនួនពីរដេរបង្កប់តាមថ្នេរខោ ពីថ្នេរចង្កេះខោរហូតដល់ចុងជើងខោទាំងសងខាងមានប៉ានឆ្នូតពីរពណ៌បៃតង ប៉ាននិមួយៗមានទទឹងប្រវែង ១.៥ ស.ម ។

-មួកកាស្កេតធ្វើអំពីក្រណាត់ពណ៌ខ្មៅ ។ ជើងមួកផ្នែកខាងមុខមានប៉ាក់ក្បាច់ភ្ញីទេសពណ៌មាស ភ្ជាប់ដោយឡេវរូបព្រះសង្ហារពណ៌មាសចំនួនពីរគ្រាប់ ។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ភ្ញីទេសពណ៌មាសពីចុងម្ខាងដល់ចុងម្ខាង ។ នៅលើមុខមួកមានដាក់រូបព្រះសង្ហារពណ៌មាសប្រភេទ ១ ។

-ពាក់ខ្សែឥស្សរិយយសពណ៌មាស នៅលើស្មាខាងស្តាំ ។

-ពាក់ស្រោមដៃពណ៌ស ។

-ក្រវាត់ខ្សែក្រវ៉ាត់ធំពណ៌មាស ពីលើអាវសំរាប់ព្យួរដាវខាងឆ្វេង ។

-ស្បែកជើងកខ្លី ពណ៌ខ្មៅ ចងខ្សែ និងស្រោមជើងពណ៌ខ្មៅ ។

## ក/២. ឯកសណ្ឋានធំលេខ ២ : " វ៉ារីពណ៌ខៀវចាស់ " :

១-ឯកសណ្ឋានធំលេខ ២ វ៉ារីពណ៌ខៀវចាស់ សំរាប់ប្រើប្រាស់ក្នុងពិធីបុណ្យជាតិ ពិធីផ្លូវការ ទទួលភ្ញៀវអន្តរជាតិ និងបំពេញបេសកកម្មនៅក្រៅប្រទេស ។

២-រូបភាព និងម៉ូត :

-អាវវ៉ារី : ដៃវែង កបើក ប៉ូលស្មា និងផែកខ្នង ។

អាវនេះមានហោប៉ៅចំនួនបួន : ហោប៉ៅខាងលើមានចំនួនពីរ ( ហោប៉ៅបិះ ) ចំកណ្តាលមានជីបផ្គត់មួយ និងហោប៉ៅខាងក្រោមមានចំនួនពីរ ( ហោប៉ៅកាត់ ) ហោប៉ៅទាំងបួនមានគំរបរាងចតុកោណកែង តែចុងគំរបសងខាង និងកណ្តាលរាងស្រួច អាវនេះមានឡេវរូបព្រះសង្ហារពណ៌មាសចំនួនបួនគ្រាប់ នៅចុងដៃអាវម្ខាង១មានឡេវរូបព្រះសង្ហារពណ៌មាសចំនួនបីគ្រាប់ដាក់បញ្ឈោត ។

-ខោ : ជើងវែង ថ្មេរបង្កប់ ចង្កេះត និងគ្មានភ្លី ។

ហោប៉ៅមានចំនួនបី : ហោប៉ៅខាងក្រោយមានចំនួនមួយ ដេរបង្កប់គ្មានគំរប និងហោប៉ៅចំហៀងទាំងសងខាង ដេរបង្កប់តាមថ្មេរខោ ។

-មួកកាស្កេតធ្វើអំពីក្រណាត់ពណ៌ខៀវចាស់ ឯរូបភាព និងម៉ូតដូចមួកកាស្កេតក្នុងឯកសណ្ឋានធំលេខ ១ ។

-អាវ : សឺមី កឌុប ដៃវែងពណ៌ផ្ទៃមេឃពាក់ខាងក្នុង ។ អាវនេះមានហោប៉ៅមួយគ្មានគំរប កាត់ស្រុងដាក់ក្នុងខោ ។

-ក្រវ៉ាត់កពណ៌ខៀវចាស់ ឃ្នាបក្រវ៉ាត់ក មានរូបសញ្ញានគរបាលជាតិប្រភេទ ៤ ពណ៌មាសនៅចំកណ្តាល ។

-ពាក់ខ្សែឥស្សរិយយសពណ៌មាសនៅលើស្មាខាងស្តាំ ។

-ពាក់ស្រោមដៃពណ៌ស ។

-ស្បែកជើងកខ្លីពណ៌ខ្មៅ ចងខ្សែ និងស្រោមជើងពណ៌ខ្មៅ ។

## ក/៣. ឯកសណ្ឋានធំលេខ ៣ : " ស្តិនស័រ " :

១-ឯកសណ្ឋានធំលេខ ៣ ស្តិនស័រ សំរាប់ប្រើប្រាស់ក្នុងពិធីសមោសរ និងពិធីជប់លៀង ។

២-រូបភាព និងម៉ូត : SK

-អាវ : ស៊ិនស័រ ដៃវែង ពណ៌ស ប៉ូលស្មា និងកាត់ខើចត្រឹមចង្កេះ ។

អាវនេះមានឡេវម្ខាង១ចំនួនបីគ្រាប់ដាក់បញ្ឆោតខាងមុខ ។ នៅចុងដៃអាវម្ខាង១ មានឡេវរូបព្រះសង្ហារពណ៌មាសចំនួនបីគ្រាប់ ដាក់បញ្ឆោត ។

-ខោ : ដូចឯកសណ្ឋានធំលេខ ១ ។

-អាវ : សឺមីកខុប ដៃវែង ពណ៌សពាក់ពីក្នុង ។ ផ្នែកខាងមុខអាវនេះ មានផ្ទេរផ្នត់តូចៗពេញផ្ទៃខាងមុខអាវ ។

-ពាក់ហើពណ៌ខ្មៅ ។

-ពាក់មួកកាស្កេតដូចឯកសណ្ឋានធំលេខ ១ ។

**ក/៤. ឯកសណ្ឋានការងារលេខ ៤ : " សាហារីយ៉ែន " :**

១-ឯកសណ្ឋានការងារលេខ ៤ សាហារីយ៉ែន សំរាប់ប្រើប្រាស់ក្នុងពិធីមិទ្ទិញ សិក្ខាសាលា ទទួលភ្ញៀវជាតិ ប្រជុំការងារ និងបំពេញការងារប្រចាំថ្ងៃ ។

២-រូបភាព និងម៉ូត :

-អាវសាហារីយ៉ែននេះ : ដៃខ្លី កបើក ពណ៌កាគី កាត់រាងអាវធំ ប៉ូលស្មា និងផែកខ្នង ។ អាវនេះមានហោប៉ៅ ចំនួនបួន : ហោប៉ៅខាងលើមានចំនួនពីរ ( ដេរប៉ះ ) នៅចំកណ្តាលមានបត់ផ្នត់មួយ និងហោប៉ៅខាងក្រោមមានចំនួនពីរ ( ដេរប៉ះ ) ចំកណ្តាលបត់ផ្នត់មួយ ។ គំរបហោប៉ៅទាំងបួនរាងចតុកោណកែង តែចុងគំរបសងខាង និងកណ្តាលរាងស្រួច ឡេវអាវរូបព្រះសង្ហារពណ៌មាស ។

-ខោ : ជើងវែងពណ៌កាគី ផ្ទេរបង្កប់ ចង្កេះត និងគ្មានភ្លី ។

ហោប៉ៅខោមានចំនួនបួន : ហោប៉ៅក្រោយមានចំនួនពីរដេរបង្កប់គ្មានគំរប ចោះរុន្ធដាក់ឡេវចំនួនមួយគ្រាប់ និងហោប៉ៅចំហៀងសងខាងដេរបង្កប់តាមផ្ទេរខោ ។

-ពាក់មួកកាស្កេតដូចឯកសណ្ឋានធំលេខ ២ ឬមួកហ្សិកកីពណ៌ខៀវចាស់ ។

-ស្បែកជើងកខ្លី ចងខ្សែពណ៌ខ្មៅ និងស្រោមជើងពណ៌ខ្មៅ ។

**ក/៥. ឯកសណ្ឋានការងារលេខ ៥ :**

១-ឯកសណ្ឋានការងារលេខ ៥ សំរាប់ប្រើប្រាស់ក្នុងពេលបំពេញការងារប្រចាំថ្ងៃ ។

២-រូបភាព និងម៉ូត : *JX*

-អាវពណ៌កាគី : កឌុប ប៉ូលស្មា និងដៃខ្លី ។

អាវនេះកាត់ស្រុង ជើងអាវវៀលដាក់ក្នុងខោ មានហោប៉ៅខាងលើចំនួនពីរ ( ដេរប៉ះ ) នៅចំកណ្តាលបត់ផ្នត់មួយ ។ គំរបហោប៉ៅមានរាងស្លឹកពោធិ ។ ឡេវអាវពណ៌កាគី ។

-ខោ : ដូចឯកសណ្ឋានការងារលេខ ៤ ។

-ពាក់ខ្សែក្រវ៉ាត់តូចពណ៌ខ្មៅ ។ ក្បាលខ្សែក្រវ៉ាត់នេះមានរូបកម្រងកួរស្រូវអមលំអរទ្រូរូបរាជសីហ៍ពណ៌មាសរាងជាស្នែងក្របី ។

-ស្បែកជើង ស្រោមជើង និងខ្សែក្រវ៉ាត់ដូចឯកសណ្ឋានធំលេខ ២ ។

-មួកកាស្កេត ដូចឯកសណ្ឋានធំលេខ ២ ឬមួកហ្សិកកីពណ៌ខៀវចាស់ ។

**ក-៦. ឯកសណ្ឋានការងារលេខ ៦ :**

១-ឯកសណ្ឋានការងារលេខ ៦ សំរាប់ប្រើប្រាស់ក្នុងពេលបំពេញការងារប្រចាំថ្ងៃ ។

២-រូបភាព និងម៉ូត :

-អាវដៃវែងពណ៌កាគី : កឌុប ប៉ូលស្មា និងចុងដៃអាវឌុប ។

អាវនេះកាត់ស្រុង ជើងអាវវៀល ដាក់ក្នុងខោ ។ អាវនេះមានហោប៉ៅចំនួនពីរ ( ដេរប៉ះ ) នៅចំកណ្តាលបត់ផ្នត់មួយ គំរបហោប៉ៅអាវមានរាងស្លឹកពោធិ ។ ឡេវអាវពណ៌កាគី ។

-ខោ ស្បែកជើង ស្រោមជើង និងខ្សែក្រវ៉ាត់ ដូចឯកសណ្ឋានការងារលេខ ៥ ។

-មួកកាស្កេត ឬ មួកហ្សិកកី ដូចឯកសណ្ឋានការងារលេខ ៥ ។

**ក/៧. ឯកសណ្ឋានការងារលេខ ៧ :**

១-ឯកសណ្ឋានការងារលេខ ៧ ពណ៌បៃតងចាស់ សំរាប់ប្រើប្រាស់ក្នុងអង្គភាពប្រតិបត្តិការមួយចំនួន ដែលកំណត់តាមប្រកាសដោយឡែករបស់ក្រសួងមហាផ្ទៃ ។

**២-រូបភាព និងម៉ូត :**

-អាវនេះមានរូបភាព និងម៉ូតដូចឯកសណ្ឋានប្រតិបត្តិការរបស់កងទ័ពជើងគោកនៃកងយោធពលខេមរភូមិន្ទ ។

អាវនេះមានហោប៉ៅចំនួនបួន : ហោប៉ៅខាងលើមានចំនួនពីរ ហោប៉ៅខាងក្រោមមានចំនួនពីរ ( ហោប៉ៅស្បោង ) ជីបមាត់ចាបចំកណ្តាល តួហោប៉ៅមូល ហោប៉ៅទាំងបួនមានគំរបបញ្ឆិតសន្ទះអណ្តាតចោះរន្ធដាក់ឡេវបង្កប់ ហោប៉ៅអាវខាងលើដាក់ឡេវចំនួនមួយគ្រាប់ ហោប៉ៅអាវខាង ៥៤

ក្រោមដាក់ឡេវចំនួនពីរគ្រាប់ពណ៌ដូចអាវ អាវដៃបំពង់ ចុងដៃអាវមានប៉ូលដាក់ឡេវចំនួនពីរគ្រាប់ ។

-ខោ : ចង្កេះលាត ជីបក្បាលជង្គង់ នៅសងខាងចង្កេះខោមានខ្សែរឹត ។ ខោមានហោប៉ៅចំនួនប្រាំមួយ ហោប៉ៅខាងក្រោយមានចំនួនពីរ ហោប៉ៅកាត់ គំរបបញ្ឆិត សន្ទះអណ្តាតចោះរន្ធដាក់ឡេវមួយគ្រាប់ ហោប៉ៅចំហៀងសងខាងមានចំនួនពីរ ( ហោប៉ៅបញ្ឆិត ) ហោប៉ៅជង្គង់មានចំនួនពីរ (ហោប៉ៅស្បោង) មានជីបផ្គត់ពីរ តួហោប៉ៅជ្រុង គំរបបញ្ឆិតមានសន្ទះអណ្តាត ចោះរន្ធដាក់ឡេវចំនួនពីរគ្រាប់ ឡេវពណ៌ដូចខោ ចុងជើងខោមានខ្សែចង ។

-ពាក់មួកបេរ៉េតពណ៌ខ្មៅ ដាក់រូបព្រះសង្ហារប្រភេទ ៣ នៅចំហៀងខាងឆ្វេងមួក ។

-ពាក់ខ្សែក្រវ៉ាត់តូចពណ៌ខ្មៅ ដូចឯកសណ្ឋានការងារលេខ ៥ ។

-ខ្សែក្រវ៉ាត់ធំ "សាំងទ្បេរ៉ុង " ពណ៌បៃតងចាស់ ក្រវ៉ាត់ពីក្រៅអាវ ។

-ពាក់ស្បែកជើងកវែងពណ៌ខ្មៅ ស្រោមជើងពណ៌ខ្មៅ ហើយជើងខោបញ្ចូលក្នុងកស្បែកជើង ។

*ខ. ឯកសណ្ឋានថ្នាក់វរសេនីយ៍ : មាន ៧ ប្រភេទ :*

រូបភាព ម៉ូត និងរបៀបប្រើប្រាស់ដូចឯកសណ្ឋានរបស់ថ្នាក់ឧត្តមសេនីយ៍ដែរ ប៉ុន្តែមានចំណុចខុសគ្នាមួយចំនួនដូចខាងក្រោម :

ខ/១-ប៉ានឆ្នូតពីរពណ៌បៃតង នៃខោឯកសណ្ឋានធំលេខ ១ ប៉ាននិមួយៗមានទទឹងតែប្រវែង ០១ ស.ម ។

ខ/២-ចំពោះមួកកាស្កេត គឺនៅលើជើងមុខមួកមានខ្សែស្ហូតាសភ្លោះពណ៌មាសវេញបញ្ចូលគ្នាបីធ្លុង និងនៅលើគែមក្បាំងមួកមានក្បាច់ភ្ញីទេសពណ៌មាស ដែលមានចុងឃ្លាតពីជើងមួកទាំងសងខាងចំងាយប្រវែង ០៤ ស.ម ។

*គ. ឯកសណ្ឋានថ្នាក់អនុសេនីយ៍ :*

គ/១-ឯកសណ្ឋានរបស់ថ្នាក់អនុសេនីយ៍មាន ៤ ប្រភេទគឺ :

ឯកសណ្ឋានធំលេខ ២ ឯកសណ្ឋានការងារលេខ ៥ លេខ ៦ និងលេខ ៧ ។

រូបភាព ម៉ូត និងរបៀបប្រើប្រាស់ដូចឯកសណ្ឋានថ្នាក់វរសេនីយ៍ដែរ ប៉ុន្តែមានចំណុចខុសគ្នាមួយចំនួនដូចខាងក្រោម :

គ/២-មួកកាស្កេត នៅលើជើងមុខមួក មានខ្សែសូតាសភ្លោះពណ៌មាស វេញបញ្ចូលគ្នាបីធ្លុង និងនៅលើគែមក្បាំងមួក មានខ្សែសូតាសភ្លោះពណ៌មាសមួយខ្សែ ។

*ឃ. ឯកសណ្ឋាននាយនគរបាលរង :*

ឃ/១-ឯកសណ្ឋានរបស់នាយនគរបាលរងមាន ៣ ប្រភេទគឺ :

ឯកសណ្ឋានការងារលេខ ៥ លេខ ៦ និងលេខ ៧ ។

រូបភាព ម៉ូត និងរបៀបប្រើប្រាស់ដូចឯកសណ្ឋានថ្នាក់អនុសេនីយ៍ដែរ ប៉ុន្តែមានចំណុចខុសគ្នាមួយចំនួនដូចខាងក្រោម :

ឃ/២-មួកកាស្កេតថ្នាក់ព្រិន្ទបាល នៅលើជើងមុខមួកមានខ្សែសយសំប៉ែតមួយបន្ទះពណ៌មាស មានទទឹងប្រវែង ១៤ ម.ម ភ្ជាប់ដោយឡេវរូបព្រះសង្ការពណ៌មាសចំនួនពីរគ្រាប់ ក្បាំងមួកពណ៌ខៀវចាស់លាត និងដាក់រូបព្រះសង្ការពណ៌មាសប្រភេទ ១ លើមុខមួក ។

ឃ/៣-មួកកាស្កេតថ្នាក់ពលបាល ដូចមួកថ្នាក់ព្រិន្ទបាលដែរ ប៉ុន្តែនៅលើជើងមុខមួកមានខ្សែសយសំប៉ែតមួយបន្ទះពណ៌ប្រាក់ មានទទឹងប្រវែង ១៤ម.ម ភ្ជាប់ដោយឡេវរូបព្រះសង្ការពណ៌មាសចំនួនពីរគ្រាប់។

នាយនគរបាលរង នៅពេលចូលរួមក្នុងពិធីបុណ្យផ្សេងៗ និងទទួលភ្ញៀវត្រូវស្លៀក-ពាក់ឯកសណ្ឋានការងារលេខ ៦ ពាក់ក្រវ៉ាត់កពណ៌ខៀវចាស់ ឃ្នាបក្រវ៉ាត់ក រូបសញ្ញានគរបាលជាតិប្រភេទ ៤ ពណ៌មាសនៅចំកណ្តាល ។

មាត្រា ២: *ឯកសណ្ឋាននគរបាលនារី :*

ក-ឯកសណ្ឋាននគរបាលនារីមាន ៤ ប្រភេទគឺ ឯកសណ្ឋានធំលេខ ២ ឯកសណ្ឋានការងារលេខ ៤ លេខ ៥ និងលេខ ៦ ។

ឯកសណ្ឋាននគរបាលនារីស្រដៀងឯកសណ្ឋាននគរបាលបុរសដែរ ប៉ុន្តែមានចំណុចមួយចំនួនខុសគ្នាដូចខាងក្រោម :

១-ឯកសណ្ឋានធំលេខ ២ (វ៉ារីពណ៌ខៀវចាស់) :

-អាវ : មានរូបភាព និងម៉ូតដូចអាវបុរសដែរ ប៉ុន្តែកាត់តាមរបៀបជាអាវនារី ។

-សំពត់ : ដីមីស្វារ៉េ ត្រឹមក្រោមក្បាលជង្គង់ ចង្កេះត ខាងមុខមានចាប់ផ្នត់និងខាងក្រោយមានឆែក ។

-ពាក់មួកសំបុកពណ៌ខៀវចាស់ ។

-ស្បែកជើងកខ្វីពណ៌ខ្មៅ និងស្រោមជើងពណ៌ខ្មៅ ។

២-ឯកសណ្ឋានការងារលេខ ៤ (សាហារីយ៉ែន):

-អាវ : មានរូបភាព និងម៉ូតដូចអាវបុរសដែរ ប៉ុន្តែកាត់តាមរបៀបជាអាវនារី ។

-សំពត់ : ដឹមីស្វារ៉េ ត្រឹមក្រោមក្បាលជង្គង់ ចង្កេះត ខាងមុខមានចាប់ផ្គត់ និងខាងក្រោយឆែក ឬខោ ។

-ពាក់មួកសំបុកពណ៌ខៀវចាស់ ។

-ស្បែកជើង និងស្រោមជើងដូចឯកសណ្ឋានធំលេខ ២ ។

៣-ឯកសណ្ឋានការងារលេខ ៥ និងលេខ ៦ រូបភាព ម៉ូត និងរបៀបប្រើប្រាស់ដូចបុរសដែរ ប៉ុន្តែស្លៀកពាក់ជាមួយសំពត់ ឬខោក៏បាន ។

-ពាក់មួកសំបុក ឬ ហ្សិកកីពណ៌ខៀវចាស់ ។

ខ-មួកសំបុកនគរបាលនារីមានរូបភាពដូចខាងក្រោម :

១-មួកសំបុកនគរបាលនារីថ្នាក់វរសេនីយ៍ : នៅលើមុខមួកមានដាក់រូបព្រះសង្ហារពណ៌មាសប្រភេទ ២ និងនៅជើងមុខមួកមានខ្សែស្ទូតាសភ្លោះពណ៌មាសវេញបញ្ចូលគ្នាបីធ្នុងមួយខ្សែ ។

២-មួកសំបុកនគរបាលនារីថ្នាក់អនុសេនីយ៍ : នៅលើមុខមួកមានដាក់រូបព្រះសង្ហារពណ៌មាសប្រភេទ ២ និងនៅជើងមុខមួកមានខ្សែសយសំប៉ែតពណ៌មាសមួយបន្ទះ ។

៣-មួកសំបុកនគរបាលនារីថ្នាក់ព្រិន្ទបាល : នៅលើមុខមួកមានដាក់រូបព្រះសង្ហារពណ៌មាសប្រភេទ ២ និងនៅជើងមុខមួកមានខ្សែសយសំប៉ែតពណ៌ប្រាក់មួយបន្ទះ ។

៤- មួកសំបុកនគរបាលនារីថ្នាក់ពលបាល : នៅលើមុខមួកមានដាក់រូបព្រះសង្ហារពណ៌មាសប្រភេទ ២ និងនៅជើងមុខមួកមានខ្សែសំប៉ែតពណ៌ខ្មៅមួយបន្ទះ ។

**មាត្រា ៣:** ឯកសណ្ឋានរបស់នគរបាលកងកិត្តិយស នគរបាលសណ្តាប់ធ្នាប់ នគរបាលចរាចរ នគរបាលទេសចរណ៍ នគរបាលតំរួតបទបញ្ជា នគរបាលព្រំដែនគោក នគរបាលអន្តរាគមន៍ នគរបាលអង្គរក្ស និងផ្លាកសញ្ញារបស់អង្គភាពនគរបាលជំនាញផ្សេង១ទៀត ត្រូវកំណត់តាមប្រកាសដោយឡែករបស់ក្រសួងមហាផ្ទៃ ។

**មាត្រា ៤:** រូបព្រះសង្ហារ និងផ្លាកសញ្ញានគរបាលជាតិកម្ពុជាត្រូវបានរៀបចំដូចខាងក្រោម :

*ក. រូបព្រះសង្ការ ៖  មាន ៣ ប្រភេទគឺ ៖*

១. រូបព្រះសង្ការប្រភេទ ១ ៖ ពណ៌មាសសំរាប់ដាក់លើមុខមួកកាស្កេត ។ រូបព្រះសង្ការប្រភេទនេះមានទំហំកំពស់ ៧៨ ម.ម និងទទឹង ៧១ ម.ម ។

២. រូបព្រះសង្ការប្រភេទ ២ ៖ ពណ៌មាសសំរាប់ដាក់លើមុខមួកហ្សិកគី និងមួកសំប៉ុកនគរបាលនារី ។ រូបព្រះសង្ការប្រភេទនេះមានទំហំកំពស់ ៥៣ ម.ម និងទទឹង ៥៤ ម.ម ។

៣. រូបព្រះសង្ការប្រភេទ ៣ ៖ ពណ៌មាស ផ្ទៃពណ៌ស រឹមព័ទ្ធជុំវិញពណ៌មាស និងមានរូបកំរងកួរស្រូវពណ៌មាសអមលំអរទ្រូរូបព្រះសង្ការរាងជាស្លែងក្របី សំរាប់ដាក់លើចំហៀងមួកបេរ៉េតើផ្នែកខាងឆ្វេង ។ រូបព្រះសង្ការប្រភេទនេះមានទំហំកំពស់ ៤៥ ម.ម និងទទឹង ៥៥ ម.ម ។

*ខ. ផ្លាកសញ្ញានគរបាលជាតិកម្ពុជា ៖  មាន ៥ ប្រភេទគឺ ៖*

១. ផ្លាកសញ្ញាប្រភេទ ១ ៖ សំរាប់ពាក់បន្តោកនៅឡេវហោប៉ៅអាវខាងស្តាំ ។

ផ្លាកសញ្ញាប្រភេទនេះ ធ្វើរាងជាមេដាយ ដែលមានស្បែកបន្តោកប្រវែង ១០០ ម.ម បាតស្រួចពណ៌ខៀវចាស់ ។ នៅលើស្បែកបន្តោកមានផ្លាកសញ្ញារាងមូល អង្កត់ផ្ចិត ៤៩ ម.ម ផ្ទៃពណ៌ខៀវចាស់ នៅចំកណ្តាលផ្ទៃមានរូបរាជសីហ៍ពណ៌មាស ពន្លឺពណ៌ប្រាក់ នៅខាងក្រោមរូបរាជសីហ៍ មានអក្សរមូលសរសេរកាត់ " **ន ម ជ ក** " ពណ៌ប្រាក់ ហើយមានរូបកងចក្រពណ៌ប្រាក់ភ្លឺមានកាំចំនួន ២១ ព័ទ្ធជុំវិញ ។

២. ផ្លាកសញ្ញាប្រភេទ ២ ៖ សំរាប់ដាក់លើដៃអាវខាងស្តាំចុះពីថ្នេរស្មាចំងាយ ៧៥ ម.ម ។

ផ្លាកសញ្ញាប្រភេទនេះធ្វើអំពីក្រណាត់រាងមូល ផ្ទៃពណ៌ទង់ជាតិ មានអង្កត់ផ្ចិតប្រវែង ៧៧ ម.ម រឹមព័ទ្ធជុំវិញពណ៌ស ទទឹង ០២ ម.ម នៅខាងលើមួយភាគបួន មានផ្ទៃពណ៌ខៀវដែលមានអក្សរមូលពណ៌ស សរសេរកាត់ថា " **ន ប** " អក្សរកំពស់ ១២ ម.ម ។ នៅផ្នែកខាងក្រោម លើផ្ទៃពណ៌ខៀវមានអក្សរឡាតាំងសរសេរថា " **POLICE** " អក្សរកំពស់ ១០ ម.ម នៅចំកណ្តាលលើផ្ទៃពណ៌ក្រហម មានរូបប្រាសាទកំពូលបីពណ៌ស ប្រាសាទមានទំហំកំពស់ ២២ ម.ម បាតប្រវែង ៣៤ ម.ម ។

៣. ផ្លាកសញ្ញាប្រភេទ ៣ ៖ សំរាប់ដាក់លើដៃអាវខាងឆ្វេងចុះពីថ្នេរស្មាចំងាយ ៥០ ម.ម ។

ផ្លាកសញ្ញាប្រភេទនេះធ្វើអំពីក្រណាត់រាងកោង ផ្ទៃពណ៌ទង់ជាតិ ទំហំបណ្តោយខាងលើ

ប្រវែង ១០៥ ម.ម បណ្តោយខាងក្រោមប្រវែង ៧០ ម.ម និងទទឹងប្រវែង ២៥ ម.ម មានរឹមព័ទ្ធជុំវិញពណ៌ស ទទឹងប្រវែង ១.៥ ម.ម ហើយនៅចំកណ្តាលផ្ទៃពណ៌ក្រហម មានអក្សរមូលពណ៌សសរសេរថា " **នគរបាលជាតិកម្ពុជា** " អក្សរកំពស់ ៨ ម.ម ។

៤. ផ្លាកសញ្ញាប្រភេទ ៤ : សំរាប់ពាក់នៅលើចុងកអាវទាំងសងខាង នៃឯកសណ្ឋានលេខ ២. ៣. ៤. ៥. និងលេខ ៦ ដោយឡែកឯកសណ្ឋានការងារលេខ ៧ ផ្លាកសញ្ញាប្រភេទនេះធ្វើអំពីក្រណាត់ប៉ាក់សំរាប់ពាក់លើចុងកអាវខាងស្តាំ ។ ចំពោះថ្នាក់ឧត្តមសេនីយ៍ និងវរសេនីយ៍ត្រូវប្រើផ្លាកសញ្ញា ប្រភេទនេះពណ៌មាស រីឯថ្នាក់អនុសេនីយ៍ចុះត្រូវប្រើផ្លាកសញ្ញាប្រភេទនេះពណ៌ប្រាក់ភ្លឺ ។

ផ្លាកសញ្ញាប្រភេទនេះ មានរាងមូល អង្កត់ផ្ចិត ២៥ ម.ម ដែលមានរូបជើងពានទ្រតំកល់រដ្ឋធម្មនុញ្ញ និងនៅខាងលើមានរូបព្រះខ័នពីរខ្វែងគ្នា ហើយមានរូបកម្រងស្លឹកជ្រៃក្រឹមអមលំអរទ្រជារាងស្នែងក្របី ដែលមានទងបំបែកចេញពីរូបផ្កាដកច័ន្ទន៏ ។

៥. ផ្លាកសញ្ញាប្រភេទ ៥ : សំរាប់ដាក់ភ្ជាប់កាបូបអត្តសញ្ញាណប័ណ្ណនគរបាលជាតិ ។

ផ្លាកសញ្ញាប្រភេទនេះ មានរាងមូល អង្កត់ផ្ចិត ៥១ ម.ម ផ្ទៃពណ៌ខៀវចាស់ រឹមព័ទ្ធជុំវិញពណ៌មាស នៅចំកណ្តាលមានរូបរាជសីហ៍ពណ៌មាស ពន្លឺពណ៌ប្រាក់ នៅខាងក្រោមរូបរាជសីហ៍មានអក្សរមូលសរសេរកាត់ថា "**ន ម ជ ត**" ពណ៌ប្រាក់ ដែលមានរូបកងចក្រពណ៌ប្រាក់ មានកាំ ២១ ព័ទ្ធជុំវិញហើយនៅផ្នែកខាងក្រោមកងចក្រ មានបដាសរសេរអក្សរឡាតាំងថា " **POLICE NATIONALE** " ពណ៌ខៀវចាស់ ។

មាត្រា ៥: ទង់នគរបាលជាតិកម្ពុជា :

ទង់នគរបាលជាតិកម្ពុជា មានផ្ទៃពណ៌ខៀវ នៅចំកណ្តាលផ្ទៃទង់មានរូបសញ្ញានគរបាលជាតិប្រភេទ ១ ដែលមានអក្សរមូលពណ៌មាសសរសេរថា : "**ក្រសួងមហាផ្ទៃ**" នៅខាងលើរូបរាជសីហ៍ និងនៅខាងក្រោម មានអក្សរមូលពណ៌មាសសរសេរថា : " **នគរបាលជាតិកម្ពុជា** " ។

មាត្រា ៦: ផ្លាកឈ្មោះ និងអត្តលេខរបស់នគរបាលជាតិកម្ពុជា ត្រូវកំណត់តាមប្រកាសដោយឡែករបស់ក្រសួងមហាផ្ទៃ ។

មាត្រា ៧: រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៨:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវទទួលអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០០០*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

លេខ ០១៦៩៧

ភ្នំពេញ, ថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០០០

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង . យូ ហុកគ្រី**

*<u>កន្លែងទទួល:</u>*

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ដូចមាត្រា ៨
- ឯកសារ - កាលប្បវត្តិ